# ផែស្ងួតក្រុមហ៊ុន BOKSENG ត្រូវបានប្រារព្ធធ្វើពិធីសម្ពោធជាផ្លូវការ



*លោកទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ថ្លែងក្នុងពិធីសម្ពោធដ៏ឧឡារិកនេះ (រូបថត អ៊ុយសុង)*

**រាជធានីភ្នំពេញ :** នៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញកាលពីថ្ងៃទី១៦ តុលា មានរៀបចំពិធីសម្ពោធផែស្ងួតរបស់ក្រុមហ៊ុន BOKSENG PPSEZ DRY PORT Co Ltd ក្រោមអធិបតីភាពលោកចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

មានប្រសាសន៍នៅក្នុងឱកាសនោះលោក ចម ប្រសិទ្ធ បានឱ្យដឹងថា ទីនេះពីមុនវាជាវាលស្រែទេ ឥឡូវបានក្លាយទៅជាតំបន់សេដ្ឋកិច្ចវិនិយោគមួយយ៉ាងធំ ហើយត្រូវបាន់ជាងគេបើប្រៀបធៀបជាមួយនឹងតំបន់សេដ្ឋកិច្ចដទៃទៀតនៅក្នុងប្រទេសកម្ពុជា ។

លោកបញ្ជាក់ថា ក្រុមហ៊ុននេះគឺជាក្រុមហ៊ុនវិនិយោគដ៏ធំមួយរបស់ប្រទេសសិង្ហបុរីដែលមានស្នាដៃល្អអស់រយៈពេលជាង៣០ឆ្នាំមកហើយក្នុងការធ្វើអាជីវកម្មលើកដាក់ដឹកជញ្ជូននៅតាមបណ្ដាប្រទេសនានា និងមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងការធ្វើអាជីវកម្មត្រួតពិនិត្យការដឹកជញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិក ។ លោករដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបន្តថា នេះគឺជាផែស្ងួតមួយដែលមានកម្មវិធីបណ្ដុះបណ្ដាល ដើម្បីឱ្យទំនិញលើកទុកលើកដាក់ដឹកជញ្ជូនចេញដំណើរបានលឿនរហ័សទាន់ចិត្ត។ បើផែស្ងួតដទៃទៀតមិនយកតំរូតាមនិងមិនបំពាក់សំភារៈបរិក្ខារទំនើបៗទេនោះ គឺអាចប្រឈមមុខនឹងការដួលរលំ ។

លោកជំទាវឧកញ៉ាលីម ឈីវហូរ អគ្គនាយកតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញបានឱ្យដឹងថា ថ្ងៃនេះក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត បានរៀបចំពិធីសម្ពោធជាផ្លូវការនូវសមិទ្ធផលថ្មីមួយក្នុងចំណោមសមិទ្ធផលមួយចំនួនទៀត ដែលបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ គឺផែស្ងួតបុកសេង ភីភីអេសអ៊ីហ្សិត ដែលជាការដាក់ទុនវិនិយោគរបស់ក្រុមហ៊ុនដឹកជញ្ជូននៅប្រទេសសិង្ហបុរី ។

តំបន់សេដ្ឋកិច្ចPPSEZ មានតួនាទីដ៏សំខាន់សំរាប់ធ្វើសម្ព័ន្ធភាព ទំនាក់ទំនង និងទាក់ទាញភ្ញៀវជាតិ-អន្តរជាតិដែលមានបំណងធ្វើវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា មកបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញនេះ ។ ដូចនេះ ពិធីសម្ពោធជាផ្លូវការនាពេលនេះគឺជាសក្ខីភាពបញ្ជាក់ថា PPSEZ សំរេចបាននូវបំណងប្រាថ្នាមួយក្នុងចំណោមគំរោងជាច្រើនដែលជាការខិតខំប្រឹងប្រែងរួមគ្នាជាមួយដៃគូក្នុងស្រុកនិងបរទេសរបស់យើងខ្ញុំ ហើយដែលមានការសំរបសំរួលទទួលស្គាល់តាមផ្លូវច្បាប់ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករនៃក្រសួង សេដ្ឋកិច្ច-ហិរញ្ញវត្ថុ និងពីស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ដែលបានអនុញ្ញាតឱ្យបង្កើតនូវ ផែស្ងួតបុកសេងភីភីអេសអ៊ីហ្សិតនេះឡើង ហើយបានបោះទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញយើងខ្ញុំ ។

ផែស្ងួត បុកសេង ភីភីអេសអ៊ីហ្សិត ចាប់ដំណើរការជាផ្លូវការ និងទទួលបានជាអាទិភាពនូវកិច្ចប្រតិបត្តិការសេវាកម្ម អាជីវកម្មផែស្ងួត ដោយផ្ដោតទៅលើសេវាកម្មដឹកជញ្ជូន ដែលមានកាតព្វកិច្ច ពីរដាច់ដោយឡែកពីគ្នា គឺ១-កាតព្វកិច្ចសេវាកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ទទួលបានប្រព្រឹត្តកម្មអនុគ្រោះជាងសន្និធិគយបណ្ដោះអាសន្ន (ផែស្ងួត) ដែលអាចធ្វើការដឹកជញ្ជូនត្រង់ចូលមកក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញតែម្ដង ក្រោមសមត្ថកិច្ចរបស់ទីស្នាក់ការគយនិងរដ្ឋាករតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ។ សេវាកម្មនេះបង្កភាពងាយស្រួលដល់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលជាមជ្ឈមណ្ឌលសំរាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ប្រមូលផ្ដុំដោយរោងចក្រ-ឧស្សាហកម្មធ្វើសកម្មភាពផលិត ពាណិជ្ជកម្មសេរី និងផលិតកែច្នៃសំរាប់ការនាំចេញ ព្រមទាំងមានមណ្ឌលសេវាកម្មមណ្ឌលលំនៅឋាន និងទេសចរណ៍ ។ ជាពិសេសទៅទៀត ជួយសំរួលដល់វិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលពុំមានទីតាំងគ្រប់គ្រាន់សំរាប់រក្សាទុកទំនិញដោយប្រការណាមួយ ។

ប្រតិកម្មអនុគ្រោះដែលទទួលបានខាងលើនេះ PPSEZ រួមជាមួយផែស្ងួត បុកសេង នឹងប្រកាន់ខ្ជាប់ក្នុងជំហរប្រតិបត្តិតាមបញ្ញត្តិប្រកាសលេខ៧៣៤ សហវ.ប្រ.ក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីនីតិវិធីគយពិសេសសំរាប់តំបន់សេដ្ឋកិច្ចពិសេស ។ ២-កាតព្វកិច្ចសេវាកម្មក្រៅតំបន់ អនុវត្តតាមនីតិវិធីគយជាធរមាន ដូចបណ្ដាផែស្ងួតផ្សេងទៀត តាមបញ្ញត្តិប្រកាសលេខ១០៦ សហវ.ប្រ.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្ដីពីសន្និធិគយបណ្ដោះអាសន្ន (ផែស្ងួត) ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្នាក់ការគយនិងរដ្ឋាករប្រចាំការនៅផែស្ងួតបុកសេង ភីភីអេសអ៊ីហ្សិត ៕ **អ៊ុយសុខ**